**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តបាត់ដំបង

សំណុំរឿងព្រហ្មទណ្ឌលេខ: ១០៥៩

ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៩

សាលក្រមព្រហ្មទណ្ឌលេខ: ១៦៦៨ "ដ"

ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២០

**ក្នុងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តបាត់ដំបង**

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តបាត់ដំបង នាថ្ងៃទីម្ភៃប្រាំ ខែវិច្ឆិកា ឆ្នាំពីរពាន់ម្ភៃ វេលាម៉ោង ប្រាំបី និង សាមសិប នាទី ព្រឹក ដោយមានសមាសភាពដូចតទៅ ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ។

លោក [redacted] ជាចៅក្រមប្រឹក្សា។

លោកស្រី [redacted] ជាចៅក្រមប្រឹក្សា។

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តបាត់ដំបង។

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តបាត់ដំបង។

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ១០៥៩ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលមាន៖

**-ជនជាប់ចោទ៖**

ឈ្មោះ [redacted] ភេទប្រុស អាយុ ៤៧ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើត ភូមិរតនៈ ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ១២៤ ក្រុមទី០៤ ភូមិរតនៈ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន ០៤ នាក់ ទោសពីមុន គ្មាន។ (ក្រៅឃុំ)

-ដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ លេខៈ ៨២២១ ត.ព្រ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០។



[redacted]

✓ ជាប់ចោទពីបទ: ក្លែងបន្លំឯកសារសាធារណៈ ប្រព្រឹត្តនៅភូមិបេង ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៨ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៦២៩ នៃក្រមព្រហ្មទណ្ឌ។

-មានលោក [redacted] អត្តលេខ ១៨០១ មានការិយាល័យឈ្មោះ សិទ្ធិស័ក្តិ ស្ថិតនៅអាគារលេខ៦៨ ផ្លូវលេខ៥៧ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិ។

**-ដើមបណ្តឹងរដ្ឋប្បវេណី**

ឈ្មោះ [redacted] ភេទប្រុស អាយុ ៦៩ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើត ភូមិបេង ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង ទីលំនៅបច្ចុប្បន្ន ភូមិបេង ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង មុខរបរ នៅផ្ទះ ប្រពន្ធឈ្មោះ [redacted] មានកូន ០៨ នាក់ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted]។

-មានលោក [redacted] អត្តលេខ ៥០៤ មានការិយាល័យផ្ទះលេខ៥៦៩ ក្រុមទី៣៣ ភូមិ១៣មករា សង្កាត់ព្រែកព្រះស្តេច ក្រុងបាត់ដំបង ខេត្តបាត់ដំបង ជាមេធាវីការពារសិទ្ធិ។

-បានឃើញ: ដីកាសន្និដ្ឋានស្ថាពរលេខ: ៣០២៥ ដស.សព ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង។

-បានឃើញ: ដីកាដំណោះស្រាយ លេខ: ១០២៩ ដ.ជ.រ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបាត់ដំបង ។

-បានឃើញ: ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: ៩១១៣ ត.ព្រ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០។

**<u>ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ</u> ៖**

កាលពីឆ្នាំ១៩៩៧ ឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] បានទិញដីមួយកន្លែងទំហំ ៥.០០០ ម៉ែត្រក្រឡា មានទីតាំងស្ថិតនៅភូមិបេង ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង ដោយមិនបានធ្វើលិខិតទិញលក់ទេ គ្រាន់តែបានប្រគល់បង្កាន់ដៃបង់ប្រាក់ និងបង្កាន់ដៃទទួលពាក្យប៉ុណ្ណោះ ពីឈ្មោះ [redacted]។ លុះនៅថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០០៨ ឈ្មោះ [redacted] បានធ្វើលិខិតផ្ទេរសិទ្ធិដីនោះ ដោយបានបន្លំស្នាមម្រាមដៃអ្នកលក់ឈ្មោះ [redacted] ហើយបានយកលិខិតនោះទៅចុះហត្ថលេខាពីអាជ្ញាធរមានសមត្ថកិច្ច។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា: ខ្ញុំបាទបានដឹងអំពីការចោទប្រកាន់ហើយ។ ខ្ញុំបាទសុំបដិសេធការចោទប្រកាន់ខាងលើ ព្រោះខ្ញុំបាទមិនបានធ្វើការក្លែងបន្លំអ្វីទេ។ ដីទំនាស់ខាងលើ គឺជាដីរបស់ខ្លួនពិតប្រាកដមែន ដែលខ្ញុំបាទទិញពីឈ្មោះ [redacted] ដោយឈ្មោះ [redacted] បានប្រគល់បង្កាន់ដៃបង់ប្រាក់ និងកាន់កាប់ដីឲ្យខ្ញុំបាទចំនួន ០៤ សន្លឹក។ ក្នុងការទិញលក់ឈ្មោះ [redacted] និងឈ្មោះ [redacted] គឺជាអ្នកផ្តិតមេដៃជាសាក្សី ចំពោះមុខមេភូមិ។ ចំពោះស្នាមមេដៃឈ្មោះ [redacted] គឺមេភូមិជាអ្នកឲ្យឈ្មោះ [redacted] ផ្តិតឲ្យ។ ខ្ញុំបាទមិនមែនជាអ្នករៀបចំធ្វើលិខិតទិញលក់ ឬឯកសារផ្ទេរសិទ្ធិអ្វីទេ គឺមេភូមិ និងអនុភូមិជាអ្នកសរសេរបំពេញឲ្យ។



[redacted]

បច្ចុប្បន្នអ្នកលក់ដីឈ្មោះ[redacted]បានស្លាប់បាត់ទៅហើយ។ ការផ្តិតមេដៃលើលិខិតនោះ គឺធ្វើនៅមេភូមិ ដោយមានខ្ញុំបាទជាអ្នកទិញ និងមានសាក្សីចំនួន ០២ នាក់ គឺឈ្មោះ [redacted] និងឈ្មោះ [redacted]។ នៅពេលនោះ ឈ្មោះ [redacted]មិនបានជួបគ្នាពេលទិញលក់ទេ។ កន្លងមក ឪពុកចុងខ្ញុំបាទឈ្មោះ[redacted] បានប្រាប់ខ្ញុំបាទថា ឲ្យលក់ដីនោះទៅ ហើយឲ្យគាត់សុំ ១.០០០ ដុល្លារអាមេរិក ដើម្បីការប្រពន្ធថ្មី។ ពេលនោះ ខ្ញុំបាទក៏បានយកបង្កាន់ដៃដីឈ្មោះ [redacted] ទៅធ្វើប្លង់ទន់ ដើម្បីយកខ្ចីប្រាក់ពីធនាគារតែម្តង។ ចំពោះលិខិតមួយដែលបានអះអាងថា ខ្ញុំបាទនឹងប្រគល់ដីខាងលើឲ្យទៅឪពុកវិញ នៅពេលដែលខ្ញុំបាទបង់ប្រាក់លស់ពីធនាគាររួចអស់។ មូលហេតុដែលខ្ញុំបាទសុខចិត្តប្រគល់ឲ្យទៅឪពុកនោះ ព្រោះខ្ញុំបាទមានចិត្តអាណិត។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានឆ្លើយថា: មូលហេតុដែលខ្ញុំបាទប្តឹងជនជាប់ចោទ ព្រោះគាត់បានធ្វើលិខិតយកដីស្រែរបស់ខ្ញុំបាទ ដែលខ្ញុំបាទទិញពីឈ្មោះ[redacted]នៅឆ្នាំ ១៩៩៧-១៩៩៨ ប៉ុន្តែមិនបានធ្វើលិខិតទិញលក់អ្វីទេ។ នៅឆ្នាំ២០០៦ ប្រពន្ធរបស់ខ្ញុំបាទបានស្លាប់ ហើយក៏បានយកបង្កាន់ដៃបង់ប្រាក់លើដីដែលបានទិញនោះ ទុកនៅឈ្មោះ [redacted]។ នៅពេលដែលខ្ញុំបាទត្រូវការប្រាក់ ខ្ញុំបាទបានឲ្យឈ្មោះ [redacted] ថា ខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលវាធ្វើការ។ ដោយខ្ញុំបាទមិនចេះអក្សរ ឈ្មោះ [redacted]បានយកឯកសារឲ្យខ្ញុំបាទផ្តិតមេដៃ ខ្ញុំបាទចេះតែផ្តិតតាមទៅ។ ក្រោយមកទៀត ទើប ខ្ញុំបាទដឹងថាឈ្មោះ[redacted]យកដីខាងលើដាក់ឈ្មោះខ្លួនឯងទៅវិញ ដោយបន្លំស្នាមមេដៃឈ្មោះ[redacted]និងឈ្មោះ [redacted]។ មូលហេតុដែលខ្ញុំបាទហ៊ានថាបន្លំ ព្រោះឈ្មោះ [redacted] និងឈ្មោះ [redacted]បានប្រាប់ខ្ញុំបាទថា មិនបានផ្តិតមេដៃឲ្យឈ្មោះ [redacted] ទេ។ ដីទំនាស់នោះ គឺខ្ញុំបាទទិញពីឈ្មោះ[redacted] ខ្ញុំបាទមិនបានផ្តិតមេដៃចំពោះមុខមេភូមិអ្វីទេ។ ខ្ញុំបាទគ្រាន់តែដឹងថាបានផ្តិតមេដៃឲ្យឈ្មោះ [redacted]ថាដើម្បីយកលុយទៅដណ្តឹងប្រពន្ធ។ ខ្ញុំបាទមិនចេះអក្សរទេ ពេលដែរឈ្មោះ [redacted] បានយកលិខិតឲ្យខ្ញុំផ្តិតនោះ គឺខ្ញុំបាទមិនបានមើលទេ គ្រាន់តែដឹងថាជាលិខិតខ្ចីលុយ។ កន្លងមកយូរឆ្នាំទើបមានខាងធនាគារមកសាកសួរ ទើបបែកធ្លាយដឹងថាឈ្មោះ[redacted] យកដីនោះទៅដាក់បញ្ចាំ។ ខ្ញុំបាទស្នើសុំឲ្យសាកសួរចម្លើយសាក្សី ឈ្មោះ [redacted] ដែលជាសាក្សីផ្តិតមេដៃនៅក្នុងលិខិតផ្ទេរសិទ្ធិ។

-សាក្សីឈ្មោះ [redacted] បានឆ្លើយថា: ខ្ញុំបាទមិនបានផ្តិតមេដៃលើលិខិតផ្ទេរសិទ្ធិរបស់ជនជាប់ចោទទេ។ ឈ្មោះ [redacted] ចេះតែដាក់ឈ្មោះរបស់ខ្ញុំបាទជាសាក្សី ប៉ុន្តែជាក់ស្តែងខ្ញុំបាទមិនបានផ្តិតមេដៃទេ។ ពេលដែលធ្វើកិច្ចសន្យា ឬលិខិតផ្ទេរសិទ្ធិអ្វីនោះ ខ្ញុំបាទមិនបានដឹងឮទេ ហើយក៏មិនបានចូលរួមដែរ។ ខ្ញុំបាទមិនបានដឹងថាជាអ្នកណាផ្តិតមេដៃកន្លែងឈ្មោះខ្ញុំបាទទេ។ ខ្ញុំបាទមិនបានដឹងឈ្មោះ [redacted] ខ្ចីប្រាក់ពីធនាគារដោយដាក់បញ្ចាំលិខិតផ្ទេរសិទ្ធិអ្វីទេ។

-ក្រឡាបញ្ជីអានសេចក្តីចម្លងរបាយការណ៍កោសលវិច័យ លេខ: ០៦៥/២០/ចល.របក/បវ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០ របស់ នាយកដ្ឋានគរបាលបច្ចេកទេស និងវិទ្យាសាស្ត្រ នៃក្រសួងមហាផ្ទៃ។

សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី: កាលពីរវៀងឆ្នាំ ១៩៩៧ ឈ្មោះ [redacted] និងប្រពន្ធបានទិញដីមួយកន្លែង ទំហំ ៥.០០០ ម៉ែត្រការ៉េ ពីឈ្មោះ[redacted]ដោយមិនបានធ្វើលិខិតផ្ទេរ



[redacted]

សិទ្ធិអ្វីទេ គ្រាន់តែប្រគល់បង្កាន់ដៃចំនួន ០៤ សន្លឹក ឲ្យឈ្មោះ[redacted]។ ហើយឈ្មោះ[redacted]បានចូលកាន់កាប់ដីនោះរហូត។ នៅឆ្នាំ២០០៦ ប្រពន្ធរបស់ឈ្មោះ[redacted]បានស្លាប់។ នៅឆ្នាំ២០០៨ ឈ្មោះ[redacted]ត្រូវការប្រាក់ការប្រពន្ធថ្មី ប៉ុន្តែគ្មានប្រាក់គ្រប់គ្រាន់ ទើបពឹងពាក់ជនជាប់ចោទឲ្យទៅខ្ចីប្រាក់ចំនួន ១.២០០ ដុល្លារអាមេរិក។ ក្រោយមកទៀត នៅអំឡុងឆ្នាំ២០១៧ គាត់បានប្រកាសលក់ដី ស្រាប់តែខាងមីក្រូហិរញ្ញវត្ថុបានចុះមកសួរនាំ ក៏មានការជជែកគ្នាដោយថាដីនោះជាកម្មសិទ្ធិរបស់ឈ្មោះ [redacted]។ ពេលដែលពិនិត្យលិខិតផ្ទេរសិទ្ធិ ចុះឆ្នាំ២០០៨ ទើបឈ្មោះ [redacted] បានទៅសួរឈ្មោះ[redacted]ទើបឈ្មោះ[redacted]បានធ្វើលិខិតបានបញ្ជាក់ថា គាត់មិនបានផ្តិតមេដៃឲ្យឈ្មោះ[redacted] ទេ។ ហើយសាក្សីឈ្មោះ [redacted]ជាសាក្សី ក៏បានបញ្ជាក់ថាមិនបានផ្តិតមេដៃជាសាក្សីឲ្យឈ្មោះ [redacted] ដែរ។ សាក្សីជាមេភូមិឈ្មោះ [redacted] បានឆ្លើយថា នៅក្នុងសំណុំរឿងផ្សេងដែលមានអង្គហេតុតែមួយ។ គាត់មិនបានរៀបចំឯកសារដូចការអះអាងរបស់ឈ្មោះ [redacted] ទេ គឺឈ្មោះ[redacted] ជាអ្នករៀបចំខ្លួនឯងទាំងអស់។ តាមឯកសារជាភស្តុតាងបញ្ជាក់ពីស្នាមមេដៃក៏បានបញ្ជាក់ថា ស្នាមមេដៃសាក្សីឈ្មោះ [redacted] គឺមិនដូចគ្នាទេ។

**សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ៖** ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]និងសាក្សីឈ្មោះ [redacted]និងតាមការពិនិត្យភស្តុតាងដែលមាននៅក្នុងសំណុំរឿង បញ្ជាក់ឲ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] ពិតជាបានក្លែងបន្លំស្នាមមេដៃរបស់សាក្សីនៅក្នុងលិខិតផ្ទេរសិទ្ធិដី ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលជាឯកសារសាធារណៈមួយប្រភេទ ពិតប្រាកដមែន។ ភស្តុតាងដាក់បន្ទុក គឺចម្លើយរបស់សាក្សី និងរបាយការណ៍កោសលវិច័យ លើស្នាមមេដៃរបស់សាក្សី។ ដូច្នេះ តំណាងអយ្យការស្នើសុំតុលាការតម្កល់បទចោទប្រកាន់ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរដដែល និងសុំឲ្យតុលាការផ្តន្ទាទោសតាមច្បាប់។

សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទៈ នៅក្នុងរឿងនេះ កូនក្តីរបស់ខ្ញុំបាទបានធ្វើឯកសារលិខិតផ្ទេរសិទ្ធិ ត្រឹមត្រូវតាមច្បាប់ ដោយមានអាជ្ញាធរដឹងឮ។ ឯកសាររបស់ឈ្មោះ [redacted]មិនអាចទទួលយកបាន ដោយគ្មានការបញ្ជាក់ពីអាជ្ញាធរ និងគ្មានកាលបរិច្ឆេទច្បាស់លាស់ ម្យ៉ាងវិញទៀត ចំពោះលទ្ធផលកោសលវិច័យស្នាមមេដៃ ក៏ម៉ែនបានបញ្ជាក់ថាស្នាមមេដៃរបស់ឈ្មោះ [redacted] ខុសគ្នាដែរ ដូច្នេះខ្ញុំបាទខ្ញុំបាទស្នើសុំឲ្យតុលាការច្រានចោលភស្តុតាងខាងលើទាំងពីរ។ សំណូមពរឲ្យកូនក្តីរបស់ខ្ញុំបាទរួចផុតពីបទចោទប្រកាន់។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted]

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]។

-ក្រោយពីបានស្តាប់ចម្លើយសាក្សីឈ្មោះ [redacted]

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹង។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

-ក្រោយពីបានពិនិត្យឯកសារភស្តុតាងនានា។



[redacted]

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

**សាលាដំបូងខេត្តបាត់ដំបង**

**យល់ឃើញថា**

១/តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌ លេខៈ ១០៥៩ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តបាត់ដំបង ដែលមានជនជាប់ចោទឈ្មោះ [redacted] ជាប់ចោទពីបទៈ ក្លែងបន្លំឯកសារសាធារណៈ ប្រព្រឹត្តនៅភូមិបេង ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៨ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៦២៩ នៃក្រមព្រហ្មទណ្ឌ តាមដីកាដំណោះស្រាយ លេខៈ ១០២៩ ដ.ជ.រ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ គប្បីតុលាការលើកយកសំណុំរឿងមកជំនុំជម្រះតាមនីតិវិធី។

២/តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា ខ្លួនពិតជាបានទិញដីពីឈ្មោះ [redacted] ដែលមានបង្កាន់ដីបង់ប្រាក់ និងយកទៅធ្វើលិខិតផ្ទេរសិទ្ធិដោយមានឈ្មោះ [redacted] និងឈ្មោះ [redacted] ជាសាក្សី និងអាជ្ញាធរដឹងឮត្រឹមត្រូវតាមច្បាប់។ តុលាការនឹងលើកយកមកពិចារណា។

៣/ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានអះអាងថា ខ្លួនជាអ្នកទិញដីខាងលើពីឈ្មោះ [redacted] ហើយខ្លួនគ្រាន់តែពឹងឲ្យកូនឈ្មោះ [redacted] ខ្ចីប្រាក់ដើម្បីរៀបការប្រពន្ធថ្មីប៉ុណ្ណោះ។ ឈ្មោះ [redacted] បានធ្លាប់ឲ្យខ្លួនផ្តិតមេដៃលើឯកសារខ្លះ ប៉ុន្តែខ្លួនមិនចេះអក្សរទេ។

៤/សាក្សីឈ្មោះ [redacted] បានអះអាងចំពោះមុខតុលាការថា ខ្លួនមិនបានផ្តិតមេដៃនៅលើលិខិតផ្ទេរសិទ្ធិដី ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៨ ទេ។

៥/តាមការពិនិត្យភស្តុតាង ជាសេចក្តីចម្លងរបាយការណ៍កោសលវិច័យ លេខៈ ០៦៥/២០/ចល.របក/បវ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០ របស់ នាយកដ្ឋានគរបាលបច្ចេកទេស និងវិទ្យាសាស្ត្រ នៃក្រសួងមហាផ្ទៃ បានសន្និដ្ឋានថា ស្នាមមេដៃសរសេរឈ្មោះ [redacted] ផ្តិតក្នុងលិខិតផ្ទេរសិទ្ធិដី ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៨ ប្រៀបធៀបជាមួយគំរូស្នាមមេដៃរបស់ឈ្មោះ [redacted] ដែលផ្តិតនៅលើឯកសារកំណត់ហេតុស្តីពីការផ្តល់ស្នាមមេដៃ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២០ គឺ មិនដូចគ្នា។

៦/តាមចម្លើយការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីឈ្មោះ [redacted] ព្រមទាំងការពិនិត្យភស្តុតាង ឃើញថា ការដែលជនជាប់ចោទឈ្មោះ [redacted] អះអាងថាខ្លួនធ្វើលិខិតផ្ទេរសិទ្ធិដី ដោយមានសាក្សីដឹងឮ គឺមិនពិតប្រាកដឡើយ។ ដូច្នេះ លិខិតផ្ទេរសិទ្ធិខាងលើមិនត្រូវបានធ្វើឡើងត្រឹមត្រូវឡើយ គឺត្រូវបានធ្វើឡើងដោយមានការក្លែងបន្លំស្នាមមេដៃរបស់សាក្សី។

៧/ថ្វីត្បិតតែ លទ្ធផលកោសលវិច័យអំពីស្នាមមេដៃមិនអាចបញ្ជាក់ពីការក្លែងបន្លំស្នាមមេដៃរបស់ឈ្មោះ [redacted] បាន ប៉ុន្តែតាមលិខិតធានាអះអាងរបស់ឈ្មោះ [redacted] បានបញ្ជាក់ថា ខ្លួនបានលក់ដីឲ្យឈ្មោះ [redacted] មិនមែនឈ្មោះ [redacted] ទេ និងសុំបដិសេធស្នាមមេដៃរបស់ខ្លួននៅលើលិខិតផ្ទេរសិទ្ធិដី ផងដែរ។

៨/មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានស្នើសុំឲ្យតុលាការច្រានចោលភស្តុតាងជាលិខិតអះអាងខាងលើ ដោយមូលហេតុថា ពុំមានកាលបរិច្ឆេទ និងគ្មានការបញ្ជាក់ពីអាជ្ញាធរត្រឹមត្រូវ ប៉ុន្តែតុលាការពិនិត្យឃើញថា



[redacted]

លិខិតខាងលើមានការបញ្ជាក់ពីអាជ្ញាធរត្រឹមត្រូវ និងបានឆ្លុះបង្ហាញពីឆន្ទៈរបស់ឈ្មោះ [redacted] ពិតប្រាកដ ផងដែរ។

៩/មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ពីបទៈ ក្លែងបន្លំឯកសារសាធារណៈ ប្រព្រឹត្តនៅភូមិបេង ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៨ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៦២៩ នៃក្រមព្រហ្មទណ្ឌ។

១០/ជនជាប់ចោទខាងលើជានីតិជន ដែលច្បាប់បានកំណត់ថាមាននីតិភាព ក្នុងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ។

១១/ជនជាប់ចោទជាជនដែលមានសតិ និងស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទ-ល្មើសដែលខ្លួនបានប្រព្រឹត្ត។

១២/ដើមបណ្តឹងរដ្ឋប្បវេណីពុំទាមទារសំណងរដ្ឋប្បវេណី គប្បី តុលាការពុំលើកយកសំណងរដ្ឋប្បវេណីមកពិចារណា។

## សាលាដំបូងខេត្តបាត់ដំបង

## វិនិច្ឆ័យសេចក្តី

១/ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ដាក់ពន្ធនាគារកំណត់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយអនុវត្តទោសព្យួរ

ពីបទៈ ក្លែងបន្លំឯកសារសាធារណៈ ប្រព្រឹត្តនៅភូមិបេង ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៨ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៦៣០ នៃក្រមព្រហ្មទណ្ឌ។

៧/សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]។

-ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និង ត្រា៖ [redacted] | ហត្ថលេខា និង ត្រា៖ [redacted] | ហត្ថលេខា និង ត្រា៖ [redacted] | ហត្ថលេខា និង ត្រា៖ [redacted] |

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

បាត់ដំបង,ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០២០

ក្រឡាបញ្ជី



[redacted]